# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ: ១៩ សសរ.កបច

## សេចក្ដីសម្រេច
## ស្ដីពីការកែសម្រួលលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់

---

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៣៦/អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

-បានឃើញសេចក្ដីសម្រេចលេខ ២០ សសរ. ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា

-បានឃើញសេចក្ដីសម្រេចបន្ថែមលេខ ៣៣ សសរ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា

-យោងតាមតម្រូវការចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១.-**

សេចក្ដីសម្រេចនេះជំនួសសេចក្ដីសម្រេចលេខ ២០ សសរ. ចុះថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០០៣ និងលេខ ៣៣ សសរ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០០៣ ដែលត្រូវទុកជានិរាករណ៍។

**ប្រការ ២.-**

លេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឡេង ប៉េងឡុង | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ប្រធាន |
| ២-ឯកឧត្តម ប៉ែន ដារ៉េត | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម ក្រាញ់ ជ.តូនី | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម ផូវ សំភី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| ៥- លោក ហ៊ីង ធីឫទ្ធិ | ចៅក្រម | អនុប្រធាន |
| ៦-លោក សេង ស៊ីវុត្ថា | ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៧-ឯកឧត្តម ទូច សីងហាយ | អគ្គលេខាធិការរងក.ប.ច. | អគ្គត្រួតពិនិត្យនិងបោះពុម្ព |
| ៨-លោក ថាច់ សែម | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ៩-លោក ស្រ៊ុន ធីរិទ្ធ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១០-លោក ស៊ា ម៉ៅ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១១-លោក អ៊ុត ស៊ីណាត | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១២-លោក ទេព សាបាន | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៣-លោក សូ ត្រៃ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការហិរញ្ញកិច្ច |
| ១៤-លោក យាង សេង | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៥-លោក ញ៉ែម សុភ័ក្រ្តា | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៦-លោក សំ រិទ្ធី | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៧-លោក កាន់ ណារិទ្ធ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៨-លោក សែម ពិសី | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការកុំព្យូទ័រ |
| ១៩-លោក ទុំ ដាវីដ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការកុំព្យូទ័រ |
| ២០-លោកស្រី ឈូក សារ៉ុ | មន្ត្រីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | ជំនួយការកុំព្យូទ័រ |

ក្នុងករណីចាំបាច់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាចតែងតាំងជំនួយការបន្ថែមតាមសំណើរបស់ប្រធានលេខាធិការដ្ឋាន ។

**ប្រការ ៣.-**

លេខាធិការដ្ឋាន គណៈកម្មការបណ្ឌិតសភា អាចអញ្ជើញអ្នកឯកទេសមកពីក្រសួងផ្សេងៗ មានក្រសួងយុត្តិធម៌ គណៈមេធាវី និងមកពីមជ្ឈដ្ឋានផ្សេងៗព្រមទាំងអ្នកជំនាញការខ្មែរ និងបរទេសនានា មកប្រឹក្សាយោបល់ ។

**ប្រការ ៤.-**

លេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា មានភារកិច្ចដូចតទៅ :

១-ព្រាងបញ្ជីពាក្យ និងបកប្រែពាក្យបរទេសមកពាក្យខ្មែរ ពិនិត្យ និងសម្រេចដើម្បីកសាងសទ្ទានុក្រមពាក្យច្បាប់

២-បោះពុម្ពឯកសារសម្រាប់ដំណើរការ ការងាររបស់គណៈកម្មការបណ្ឌិតសភាទាំងមូល

៣-រៀបចំការប្រជុំរបស់គណៈកម្មការបណ្ឌិតសភា

៤-ធ្វើកំណត់ហេតុ និងរបាយការណ៍នៃអង្គប្រជុំ

៥-រៀបចំចងក្រង និងបោះពុម្ពពាក្យដែលអង្គប្រជុំបានអនុម័ត

៦-រៀបចំបោះពុម្ពសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល ។

**ប្រការ ៥.-**

លេខាធិការដ្ឋានអនុវត្តការងារក្រោមការដឹកនាំរបស់ប្រធាន ។

**ប្រការ ៦.-**

សេចក្តីសម្រេចនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ